ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 12-Aug-2013, 11:50
CMS/CFO: Krystal THOMPSON

**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ៖ ០០២/១៩-០៩-២០០៧-អវតក/អជសដ

ភាគីដាក់ឯកសារ៖ លោក **ខៀវ សំផន**

ដាក់ជូន៖ អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម៖ **បារាំង**

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០១៣

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ៖ **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង៖ **សាធារណៈ/Public**

ប្រភេទនៃចំណាត់ថ្នាក់៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន៖

ឈ្មោះមន្ត្រីទទួលបន្ទុកផ្នែកសំណុំរឿង និងឯកសារ៖

ហត្ថលេខា៖

---

**ព័ត៌មានអំពីពេលវេលាចាំបាច់សម្រាប់ការធ្វើសេចក្ដីសន្និដ្ឋានស្ដាពរ**

---

| ដាក់ដោយ៖ | ដាក់ជូន៖ |
|---|---|
| **មេធាវីការពារក្ដីលោក ខៀវ សំផន** | **អង្គជំនុំជម្រះសាលាដំបូង៖** |
| មេធាវី គង់ សំអុន | ចៅក្រម និល ណុន |
| មេធាវី Anta GUISSÉ | ចៅក្រម Silvia CARTWRIGHT |
| មេធាវី Arthur VERCKEN | ចៅក្រម យូរ ឧត្ដារា |
| មេធាវី Jacques VERGÈS | ចៅក្រម Jean-Marc LAVERGNE |
| | ចៅក្រម យ៉ា សុខន |

**ជំនួយការ៖**

លោកស្រី សេង សុជាតា

កញ្ញា Marie CAPOTORTO

កញ្ញា Mathilde CHIFFERT

កញ្ញា Soumeya MEDJEBEUR

កញ្ញា Vera MANUELLO

កញ្ញា អ៊ូច ស្រីផាត់

លោក សេង ឆេងហួរ

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Andrew CAYLEY

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

**ក្រុមមេធាវីការពារក្តីទាំងអស់**

# គោរពជូនអង្គជំនុំជម្រះសាលាដំបូង

១. នៅថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៣ អង្គជំនុំជម្រះសាលាដំបូង ("អង្គជំនុំជម្រះ") បានជូនដំណឹងដល់ភាគីថា ក្រោយពេលធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរួច *"អង្គជំនុំជម្រះនឹងផ្តល់ពេលវេលាទៅក្រុមមេធាវីការពារក្តី និង/ឬ ជនជាប់ចោទ ដើម្បីធ្វើសេចក្តីសន្និដ្ឋានស្ថាពរ"*[1]។

២. នៅថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១៣ អង្គជំនុំជម្រះបានចេញកាលវិភាគ ដោយមិនទុកពេលវេលាឲ្យអនុវត្តសិទ្ធិនេះ ស្របតាមវិធាន ៩៤(៣) នៃវិធានផ្ទៃក្នុង ដែលចែងថា *"នៅគ្រប់ករណីទាំងអស់ ជនជាប់ចោទ និងមេធាវីរបស់ជនជាប់ចោទត្រូវតែមានសិទ្ធិធ្វើសេចក្តីសន្និដ្ឋានចុងក្រោយជានិច្ច"*[2] នោះទេ។

៣. នៅថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១៣ មេធាវីការពារក្តីលោក ខៀវ សំផន បានស្នើសុំឲ្យអង្គជំនុំជម្រះបំភ្លឺចំពោះការភ្លេចដ៏ច្បាស់ក្រឡែតនេះ[3]។

៤. នៅថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១៣ អង្គជំនុំជម្រះបានបង្គាប់ឲ្យជនជាប់ចោទ *"ជូនដំណឹងមកអង្គជំនុំជម្រះ ត្រឹមថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០១៣ អំពីថិរវេលាតាមការប៉ាន់ប្រមាណ ដែលចាំបាច់ដើម្បីធ្វើសេចក្តីសន្និដ្ឋានរៀងៗខ្លួនរបស់ពួកគាត់"*[4]។

---

[1] កាលបរិច្ឆេទសម្រាប់សវនាការដេញដោលលើឯកសារជាលើកចុងក្រោយ និងសវនាការផ្សេងៗ នៅក្នុងសំណុំរឿង ០០២/០១ សម្រាប់ការសួរសំណួរទៅជនជាប់ចោទ និងចម្លើយតបទៅនឹងសំណើ E263 និងសំណើ E288/1 ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ E288/1/1 កថាខណ្ឌ ១២។

[2] ការបញ្ជាក់ពីកាលបរិច្ឆេទនៃការដាក់សារណា និងសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល ចុះថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១៣ ឯកសារ E295។

[3] សំណើរបស់មេធាវីការពារក្តីលោក ខៀវ សំផន សុំបំភ្លឺអំពីកាលវិភាគនៃការធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១៣ ឯកសារ E295/1។

[4] ចម្លើយតបទៅនឹងសំណើរបស់ ខៀវ សំផន ស្នើសុំការបញ្ជាក់បំភ្លឺពាក់ព័ន្ធនឹងការធ្វើសេចក្តីសន្និដ្ឋានបិទបញ្ចប់ការពិភាក្សាដេញដោល (ឯកសារ E295/1) ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១៣ ឯកសារ E295/1/1 កថាខណ្ឌ ២ (សំណៅចម្លងនៃអនុស្សរណៈនេះជាភាសាបារាំង)។

៥. ថ្ងៃនេះ មេធាវីការពារក្តីលោក ខៀវ សំផន សូមជម្រាបជូនអង្គជំនុំជម្រះថា យើងខ្ញុំត្រូវការពេលវេលា ៦ ម៉ោង សម្រាប់សេចក្តីសន្និដ្ឋានស្ថាពររបស់ជនជាប់ចោទ និង/ឬ មេធាវីការពារក្តី។

| | | | |
|---|---|---|---|
| | មេធាវី គង់ សំអុន<br><br>មេធាវី Anta GUISSÉ<br><br>មេធាវី Arthur VERCKEN | ទីក្រុងភ្នំពេញ<br><br>ទីក្រុងប៉ារីស<br><br>ទីក្រុងប៉ារីស | |